សម្លេងខ្មែរនៅបរទេស

# ពីនាគរាជ ទៅពស់ព្រលិត

ដោយ អ៊ុម-ហាក់ ★ ថ្ងៃទី១០ សីហា ២០០៥

មុនយាងចូលស្រុកខ្មែរកាលពីខែកក្កដា២០០៥ សម្តេចសីហនុបានសន្យាជាឧឡាឫកថា នឹងមិននិយាយស្តីឬសរសេរអំពីអ្វី ដែលធ្វើឲ្យវរជនខ្មែរធំៗអាក់អន់ស្រពន់ចិត្តឡើយ ដើម្បីចៀសវាងកុំឲ្យគ្រាប់បែកបរមាណូ ធ្លាក់លើព្រះកេស(ក្បាល)របស់ព្រះអង្គ ។ ទ្រង់បានបន្ថែមថា ទ្រង់មិនមែនកំសាកទេ តែព្រះអង្គចាស់ជរាណាស់ទៅហើយ (យើងមិនយល់មិនដឹងថាព្រះអង្គចង់មានន័យថាម៉េច?) ។

ពេលគង់នៅស្រុកខ្មែរ ខែកក្កដានិងសីហា សកម្មភាពធំបំផុតរបស់ព្រះអង្គគឺថតកុននៅមហាវិទ្យាល័យវិចិត្រសិល្បៈ សម្ពោធអំណោយខ្លះៗលើរូបថតនៅក្នុងវាំង អញ្ជើញប្រជាពលរដ្ឋមកវាំងដើម្បីសួរសុខទុក្ខ និងសមាទាន«សីល»នៅក្នុងវាំង ។

ក្រឡេកមួយភ្លែតទៅ គេឃើញថាសកម្មភាពទាំងឡាយនោះ បានប្រព្រឹត្តទៅនៅក្នុងវាំងនិងទីជិតៗតែប៉ុណ្ណោះ ។ តើសម្តេចជរាថ្នាក់ចេញទៅជួបសុខទុក្ខប្រជាពលរដ្ឋដល់ខេត្តក្រុង និងសម្ពោធអំណោយរបស់ព្រះអង្គដល់ទីកន្លែងលែងបានហើយឬ ? ឬមួយក៏ព្រះអង្គចង់យាងទៅណាក៏បានដែរ គ្រាន់តែមិនមាននរណាអើពើធានាសន្តិសុខថ្វាយ ? ឬមួយក៏ព្រះអង្គបានក្លាយទៅជ ា«គ្រាប់ព្រឹង» ដែលពួកកុម្មុយនិស្ត«ខ្វាក់ចោល»ទៅហើយ ? ។

គួររំឭកឡើងវិញដែរថា កាលពីឆ្នាំ១៩៧៣ ក្នុងនាមជាប្រមុខរដ្ឋក្រៅស្រុក សម្តេចបានយាងទស្សនាស្រុកខ្មែរម្តងហើយ តែពួកខ្មែរកុម្មុយនិស្តមិនបានអនុញ្ញាតឲ្យព្រះអង្គជួបរាស្ត្រខ្មែរទេ ។



ពេលសម្តេចសីហនុនិងអ្នកម្នាងម៉ូនិកទស្សនា«តំបន់រំដោះ»កាលពីឆ្នាំ១៩៧៣ គឺយួនបានដឹកព្រះអង្គចេញពីទីក្រុងហាណូយ ចុះតាមផ្លូវលំហូ-ជីមិញ កាត់តំបន់សាមឿនៅស្រុកលាវ មុនចូលដល់ខេត្តសៀមរាប ។ រូបភាពខាងលើ សម្តេចកំពុងធ្វើសេចក្តីថ្លែងការណ៍ទៅកាន់ សមាជិកទាំងអស់នៃ«រណសិរ្ស និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» ដែលព្រះអង្គជាព្រះប្រធានដ៏មហិមា ។

សម្តេចសីហនុមិនមែនជាមនុស្សដែលរស់នៅស្ងៀមស្ងាត់ ត្រូវគេបំភ្លេចចោលបាននោះឡើយ ។ ជោគជ័យបន្តិចបន្តួចដែលបានមកពីការថតកុន ល្ខោន និងចំរៀងរបស់ព្រះអង្គ បើបោកប្រាស់អ្នកដ៏ទៃមិនសូវបាន ក៏វាអាចជួយលួងលោមព្រះអង្គឯងបានខ្លះៗដែរ ។ សម្តេចរមែងតែងតែបង្កើតរឿងផ្សេងៗ ធ្វើឲ្យគេឯងភ្ញាក់ផ្អើលជានិច្ច មិនទុកពេលឲ្យគេភ្លេចព្រះអង្គឡើយ ។ ប្រហែលដោយហេតុនេះហើយ ទើបបានជាលេចរឿងយាយចាស់តាចាស់ ព្រមានសម្តេចពេលថ្មីៗនេះ ។ សេចក្តីព្រមានដែលមានចែងក្នុង<វែបសាយ> របស់ព្រះអង្គ ចុះថ្ងៃទី៨កក្កដា២០០៥ មានសេចក្តីជាអាទិថា « <គេ>កំពុងរៀបចំកម្លាំងទ័ពដើម្បីវាយប្រហារខ្ញុំ តាមផ្លូវកាយដោយចាប់ចងធ្វើទារុណកម្ម រួចសម្លាប់ខ្ញុំថ្ងៃណាមួយ ព្រោះតែសំណេរនិងសំដីរបស់ខ្ញុំខ្លះ ធ្វើឲ្យ<គេ>អាក់អន់ស្រពន់ចិត្ត» ។ ពាក្យ<គេ>ដែលសម្តេចសីហនុលើកឡើងនេះ គឺព្រះអង្គចង់សំដៅទៅរកលោកហ៊ុន-សែន ។ សេចក្តីព្រមាននេះវាមានមែនឬក៏ជាការប្រឌិតឡើងដើម្បីបង្វែរអារម្មណ៍អ្នកផង ពីរឿងមួយទៅរឿងមួយទៀត ? តួអង្គយាយចាស់ តាចាស់ តារួមរឹត ជាតួអង្គមែនទែនជាតួអង្គកាន់កូនខ្មោច ឬក៏ជាតួអង្គជប់ ? ហេតុអ្វីបានជាសម្តេចសីហនុយករឿងនេះ និងអ្នកអស់នេះមកចុះផ្សាយក្នុង<វែបសាយ>របស់ព្រះអង្គ ? ការពិតមានតែសម្តេចម្នាក់គត់ដែលជ្រាប ។ តួអង្គមានពិតឬអត់ សេចក្តីព្រមាននោះមានពិតឬអត់ មិនជាការសំខាន់ទេ តែផលវិបាកនៃរឿងទើបសំខាន់ ហើយត្រូវពិចារណា ។

បើមាននរណាជឿថា លោកហ៊ុន-សែនរៀបចំទ័ពដើម្បីចាប់ចង ធ្វើទារុណកម្ម រួចសម្លាប់សម្តេច អ្នកនោះប្រហែលច្រឡំធំហើយ ។ លោកហ៊ុន-សែនប្រហែលមិនចេះដើរតួកុនឬល្ខោនទេ តែលោកជាអ្នកលេងអុកយ៉ាងប៉ិនប្រសប់ម្នាក់ ។ ក្នុងល្បែងនេះ គេមិនអាចសម្លាប់ស្តេចបានទេ កាលបើគូប្រកួតនៅសល់កូនអុកប៉ុន្មានបន្សំច្រើនការពារ ។ «អញអត់ធើអីអ្ហែងទេ តែអញកាត់ដៃកាត់ជើងអ្ហែងឲ្យអស់» នេះជាសំដីរបស់ហ៊ុន-សែន កាលពីរដ្ឋប្រហារថ្ងៃ៥-៦កក្កដា១៩៩៧ ។ មែន ! ទ្រង់រណឫទ្ធិបានភៀសខ្លួនរួចទៅទៅស្រុកបារាំងសែស ចំណែកឯកូនចៅរបស់ទ្រង់បានត្រូវ <គេ>កាត់អណ្តាត កាត់ត្រចៀក ខ្វេះភ្នែក វះពោះ សម្លាប់ចោលអស់រាប់រយ ។ ទ្រង់រណឫទ្ធិខ្សត់កូនចៅការពារ ក៏បានក្លាយទៅជាកូនសំពាយរបស់ហ៊ុន-សែនទៅហើយ ។ ចុះព្រះបិតាវិញ តើហ៊ុន-សែនល្ងង់ថ្នាក់ដល់ទៅចាប់ចង ធ្វើទារុណកម្ម រួចសម្លាប់សម្តេចសីហនុឬ ? ។

សម្តេចសីហនុមានប្រាជ្ញាឆ្លាតវៃគួរឲ្យព្រឺដែរ ។ មុននឹងដាក់រាជ្យ ទ្រង់សីហមុនីត្រូវតែធានាបានឡើងសោយរាជ្យ រីឯតួសម្តេច ព្រះអង្គក៏ត្រូវតែមានច្បាប់ការពារមិនឲ្យនរណាប៉ះពាល់បានឡើយ (សូមមើលច្បាប់«ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ» គេបានឆ្លៀតបង្កើតជំពូកពិសេសមួយក្នុងមាត្រាទី១៦សរសេរយ៉ាងដូច្នេះថា «ព្រះមហាក្សត្រដែលទ្រង់ស្តេចយាងចូលនិវត្តន៍ឬដាក់រាជ្យនិងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិអភ័យឯកសិទ្ធិពេញលេញនឹងពុំអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គគ្រងរាជសម្បត្តិ» មាត្រានេះជាមាត្រាពុំចាំបាច់ ហើយក៏គ្មានពាក់ព័ន្ធអ្វីនឹង«ការរៀបចំនិងការប្រព្រឹត្តនៃក្រុមប្រឹក្សារាជសម្បត្តិ» ផងដែរ ) ។ ដូចនេះរឿងចាប់ចង ធ្វើទារុណកម្មលើតួអង្គសម្តេច គឺជារឿងប្រឌិតសុទ្ធសាធ ។ បើគ្មាននរណាអាចប៉ះពាល់ដល់សម្តេចបាននោះ តើលោកហ៊ុន-សែននឹងធ្វើយ៉ាងណា ? លោកហ៊ុន-សែនបានព្រមានរួចហើយថា កុំស្នើច្បាប់ កុំធ្វើបាតុកម្មទាមទារអំណាចថ្វាយសម្តេចឲ្យសោះ «ចាប់» «ចាប់» ព្រោះអំពើនេះជា«រដ្ឋប្រហារ»ប្រឆាំងរដ្ឋាភិបាល ហើយលើកនេះ «អត់មានតុលាការទេ ព្រោះគង់តែលើកលែងទោសដដែលជាដដែល», លោកហ៊ុន-សែនបញ្ជាក់បន្ថែម ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ តួអង្គសម្តេចសីហនុមិនមាននរណាប៉ះពាល់បានឡើយ តែអ្នកហែរហមត្រូវប្រុងប្រយ័ត្នឲ្យណាស់ ។ មកទល់ពេលនេះហ៊ុន-សែនមិនដែលខានប្រើអំពើឃោរឃៅរបៀបភេរវកម្មទៅលើនរណា ដែលទើសទែងដល់ការពង្រឹងអំណាចរបស់គាត់ដល់ម្តងណាឡើយ ។ រីឯសម្តេចសីហនុវិញគេមនដឹងថា ព្រះអង្គប្រាកដជាចង់ដោះស្រាយបញ្ហាព្រំដែនមែនពិត ឬក៏គ្រាន់តែអង្រួនមតិទូទៅកុំឲ្យភ្លេចព្រះអង្គប៉ុណ្ណោះទេ ? ។ បើនិយាយពីអ្នកគាំទ្រព្រះអង្គវិញ បើប្រទះគ្រោះអាសន្ន ទទួលខ្លួនឯងទៅ ព្រោះចំពោះមុខហ៊ុន-សែន សម្តេចបានប្រែរូបពីនាគរាជទៅជាពស់ព្រលិតទៅហើយ អត់ជួយនរណាបានទេ ។ ព្រះអង្គថែមទាំងបានបញ្ជាក់ចុងក្រោយថា គាំទ្រនិងគាំទ្រលោកហ៊ុន-សែនលុះអស់ព្រះជន្ម ។ ភ្លឺភ្នែកគ្រប់ៗគ្នាខ្លះហើយឬនៅ ?? ។៚